ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ: ០២

ថ្ងៃទី០៥ខែមករាឆ្នាំ១៩៩៨

សាលដីកា

លេខ: ៣៧

ថ្ងៃទី០៣ខែធ្នូ ឆ្នាំ ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក យស់ ហួរឡៀន ជាចៅក្រមរបាយការណ៍

លោក វ៉ុក ប៊ូរ៉ាត ជាក្រឡាបញ្ជី

តំណាងមហាអយ្យការលោក ដួន ញ៉ិនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ០២ ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

ពីបទ: ជេរប្រមាថប្រព្រឹត្តកាលពីថ្ងៃទី ២៣-៣-៩៥ នៅភូមិវត្តចេក២ ឃុំរតនៈ ស្រុកស្វាយចេក ខេត្តបាត់ដំបង បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

- ជនជាប់ចោទឈ្មោះ ង៉ែត វណ្ណៈ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិ ខ្មែរ កើតនៅភូមិ បន្ទះឡាន ឃុំឥដ្ឋការស្រុកដង្កោរ ខេត្តកណ្តាល មុខរបរ បញ្ញាវន្ត មានទីលំនៅសព្វថ្ងៃ ភូមិវត្តចេក២ ឃុំរតនៈ ស្រុកស្វាយចេក ខេត្តបាត់ដំបង ឪពុកឈ្មោះ ជាប៉ូច "ស្លាប់" ម្តាយឈ្មោះ ឈូ ទៀន "ស្លាប់" ប្រពន្ធឈ្មោះ ប្រាក់ សុផារី មានកូនម្នាក់ ។

- មេធាវី គ្មាន

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះសំ ជឿន "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករ មានទីលំនៅសព្វថ្ងៃភូមិល្អក់១ ឃុំរតនៈ ស្រុកស្វាយចេក ខេត្តបាត់ដំបង។

- មេធាវី គ្មាន ។

- តាមបណ្ដឹងសាទុក្ខលេខ៣៧០ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៧ របស់ជនជាប់ចោទ ឈ្មោះ ទែកន វណ្ណៈ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- តាមពាក្យបណ្ដឹងចុះថ្ងៃទី ១១ - ៤ - ៩៥ របស់ឈ្មោះ សំ ជឿន ប្ដឹងពីឈ្មោះ ទែកន វណ្ណៈ ដោយចោទថា នៅថ្ងៃទី១៦ - ១ - ៩៥ ឈ្មោះ ទែកន វណ្ណៈ បានមកហៅខ្លួនទៅស្នាក់បាប់ត្រីនៅ អាងកៀស ដោយអោយកំរៃខ្លួនក្នុងមួយថ្ងៃ០១ម៉ឺនរៀល លុះធ្វើការបាន១០ថ្ងៃខ្លួនទៅសុំទែកន វណ្ណៈ ត្រឡប់មកផ្ទះវិញ ហើយឈ្មោះទែកន វណ្ណៈ បានសុំខ្ចីចបរបស់ខ្លួនទុកប្រើសិន លុះក្រោយមកខ្លួនក៏ទៅ ទារចបរបស់ខ្លួនវិញ ប៉ុន្តែពុំបានចបមកវិញទេ ខ្លួនក៏ទារលុយ ១០០បាតដើម្បីទិញចបថ្មីរបស់ខ្លួន ស្រាប់តែឈ្មោះ ទែកន វណ្ណៈ ចេញពីក្នុងផ្ទះ និយាយតំរោះតំហើយចាក់ខ្លួនតែម្ដង ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តបាត់ដំបងថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ទែកន វណ្ណៈ ពីបទ ជេរប្រមាថ ប្រព្រឹត្តនៅភូមិវាំងបេក២ ឃុំរតនៈ ស្រុកស្វាយពៅ ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៣ - ៣ - ៩៥ តាមបញ្ញត្តិមាត្រា ៦៣ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ - ៩ - ៩២ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៦០ ចុះថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់តុលាការខេត្តបាត់ដំបង ដែលបានសំរេច ៖

១ - ផ្ដន្ទាទោសដាក់ពន្ធនាគារលើឈ្មោះ ទែកន វណ្ណៈ ភេទប្រុស អាយុ ៣៦ ឆ្នាំ កំណត់ ៦ខែតែទោសនេះត្រូវព្យួរទោស៖ ពេលសាកល្បង២ឆ្នាំគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។ ពីបទជេរប្រមាថ ប្រព្រឹត្តនៅភូមិវាំងបេក២ ឃុំរតនៈ ស្រុកស្វាយពៅ ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៣-០៣ - ៩៥ ។ តាមបញ្ញត្តិមាត្រា៦៣និង៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ - ៩ - ៩២ ។

២ - អោយឈ្មោះ ទែកន វណ្ណៈ សងសំណងជំងឺចិត្តជាប្រាក់ ២០ម៉ឺនរៀលទៅអោយ សំ ជឿន ជាជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណី ទាមទារលើសពីនេះបដិសេធចោល ។

ក្នុងករណីទណ្ឌិតខាងលើគ្មានប្រាក់សងធនទណ្ឌគ្រប់ចំនួនទេនោះត្រូវដាក់គុកបង្ខំរូបរាងដើម្បីទារប្រាក់ធនទណ្ឌរយៈពេល៣០០ថ្ងៃ ។

៣ - សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ទុករយៈពេលប្ដឹងទាស់ និង ឧទ្ធរណ៍តាមច្បាប់កំណត់ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ២០ ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ របស់ឈ្មោះ ទែកន វណ្ណៈ ដែលប្ដឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៣៦០ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់តុលាការខេត្តបាត់ដំបង លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ ស្នើតម្កល់សាលក្រមតុលាការខេត្តទុកជាបានការ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៩៧ -

របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៦ - ០២ - ៩៦ របស់ជនជាប់ចោទឈ្មោះ កែវ វណ្ណៈ ទុកជាត្រឹមត្រូវតាមទំរង់ និងនីតិច្បាប់ ។

២ - បដិសេធសាលក្រមលេខ ៣៦០ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់តុលាការខេត្តបាត់ដំបងចោលជាអសារបង់ ។

៣ - ផ្តន្ទាទោសឈ្មោះ កែវ វណ្ណៈ ភេទប្រុស អាយុ ៣៦ ឆ្នាំ អោយបង់ប្រាក់ពិន័យ ចំនួន ៣០ ម៉ឺនរៀលចូលថវិការរដ្ឋពីបទ ជេរប្រមាថ ប្រព្រឹត្តនៅភូមិ រំចេក២ ឃុំ រតនៈ ស្រុក ស្វាយទៅ ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៣ - ៣ - ៩៥ តាមបញ្ញត្តិមាត្រា ៦៣. ៦៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤ - សាលដីកានេះប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣៧០ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ របស់ឈ្មោះ - កែវ វណ្ណៈ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ កែវ វណ្ណៈ ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: ជនជាប់ចោទបានជេរប្រមាថ ហើយមានការប្រើប្រាស់អាវុធខុសច្បាប់ថែមទៀត ប៉ុន្តែដោយអយ្យការមិនបានចោទប្រកាន់ ដូចនេះសាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ សូមតុលាការពិនិត្យពិចារណា ។

- បានស្តាប់សំអាងសារណារបស់ជនជាប់ចោទ ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណា របស់ជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៧០ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ របស់ឈ្មោះ កែវ វណ្ណៈ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទក្នុងសារណាចុះថ្ងៃទី ១៩ - ៣ - ៩៨ ថា ខ្លួនពុំបានជេរទៅឈ្មោះ សំ ដឿនទេនោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា មាន -

កណ្ដាលគ្រប់គ្រាន់បញ្ជាក់ថា កាលពីថ្ងៃទី ២៣-៣-៨៥ ឈ្មោះ កែវ វណ្ណៈ ពិតជាបានជេរប្រមាថលើឈ្មោះ សំ ជឿន ប្រាកដមែន ។

- យល់ឃើញថា ជនជាប់ចោទបានផ្ញើសារណាជូនមកតុលាការកំពូលហើយ ដើមបណ្ដឹងរដ្ឋប្បវេណីបានចាកចេញពីទីលំនៅមិនដឹងទៅរស់នៅទីណាទេ តាមចំណារចុះថ្ងៃទី ០៩-៤-៨៨ របស់មេឃុំលេខ១ ឃុំរតនៈ ស្រុកស្វាយទៀប អ្នកទាំងពីរពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខអ្នកទាំងពីរ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីកំបាំងមុខជនជាប់ចោទនិងដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសាទុក្ខលេខ ៣៧០ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៨៧ របស់ឈ្មោះ កែវ វណ្ណៈ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨៨ ។